ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ ១៤៩ សអ.១៥អអក

ភ្នំពេញ, ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥

# លិខិតអនុញ្ញាត

## អាជ្ញាធរអគ្គិសនីកម្ពុជា

- អនុវត្តតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខនស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១
- អនុវត្តតាមការកំណត់របស់អនុក្រឹត្យ លេខ៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី
- អាជ្ញាប័ណ្ណរួមលេខ៣១៣.អ ដែលបានចេញឲ្យលោក ឈឹម សារោទិ៍ នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១
- យោងសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា លេខ០៦៥.សរ-១៥-អអក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥
- យោងតាមតម្លៃប្រេងម៉ាស៊ូតលើទីផ្សារ ក្នុងខែមករា ឆ្នាំ២០១៤
- យោងតាមចំណារឯកភាពលើកំណត់បង្ហាញរបស់នាយកដ្ឋានបញ្ជីថ្លៃលក់ និងត្រួតពិនិត្យគណនេយ្យសេវាកម្ម លេខ០២៩-១៥-បថល ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥

## អនុញ្ញាត

**ប្រការ ១** -

ផ្អែកតាមតារាងថ្លៃលក់អគ្គិសនីនៅក្នុងប្រការ១ នៃសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា លេខ០៦៥.សរ-១៥-អអក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ និងផ្អែកលើមូលដ្ឋានថ្លៃប្រេងម៉ាស៊ូតនៅលើទីផ្សារជាមធ្យម នៅក្នុងខែធ្នូ ឆ្នាំ២០១៤ មានតម្លៃស្មើនឹង ៧៥៧ (ប្រាំពីររយហាសិបប្រាំពីរ) ដុល្លារអាមេរិកក្នុង១តោន អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចអនុញ្ញាតឲ្យសេវាករ ឈឹម សារោទិ៍ អ្នកកាន់អាជ្ញាប័ណ្ណលេខ៣១៣.អ ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់ទូទៅ នៅឃុំចុងកាល់ និងឃុំជើងទៀន ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ បញ្ចុះអត្រាថ្លៃលក់មកត្រឹម ២,០០០ (ពីរពាន់) រៀលក្នុង១គីឡូវ៉ាត់ម៉ោង។

**ប្រការ ២** -

អត្រាថ្លៃលក់អគ្គិសនីថ្មីខាងលើនេះ ត្រូវបានអនុញ្ញាតឲ្យអនុវត្តចំពោះការចេញ"វិក្កយបត្រថ្លៃអគ្គិសនី" ចាប់ពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ តទៅ រហូតដល់មានការអនុញ្ញាតជាថ្មីដោយអាជ្ញាធរអគ្គិសនីកម្ពុជា ទៅតាមកម្រិតថ្លៃប្រេងម៉ាស៊ូតលើទីផ្សារ។ អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវផ្លាស់ប្តូរខួប និងពេលវេលាក្នុងការកត់ត្រាលេខអំណាននាឡិកាស្ទង់ កាលបរិច្ឆេទនៃការចេញវិក្កយបត្រថ្លៃអគ្គិសនី និងការបែងចែកក្រុមអតិថិជនទេ ក្នុងការអនុវត្តអត្រាថ្លៃលក់អគ្គិសនីថ្មីខាងលើ។ បញ្ជីថ្លៃលក់អគ្គិសនីចាស់ដែលបានដាក់ឱ្យប្រើប្រាស់ត្រូវចាត់ទុកជានិរាករណ៍ ចាប់ពីពេលអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីថ្មីនេះ។

**ប្រការ ៣** -

ការអនុវត្តអត្រាថ្លៃលក់អគ្គិសនីនេះ មានប្រសិទ្ធភាពអនុវត្តចំពោះអ្នកប្រើប្រាស់អគ្គិសនីដែលឋិតនៅក្នុងតំបន់ចែកចាយរបស់សេវាករ ឈឹម សារពេទ៏ ប៉ុណ្ណោះ ។

**ប្រការ ៤** -

សេវាករ ឈឹម សារពេទ៏ មានភារកិច្ចផ្សព្វផ្សាយអំពីការអនុញ្ញាតនេះ ដល់អតិថិជនរបស់ខ្លួនគ្រប់ប្រភេទដែលពាក់ព័ន្ធ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**
**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**

<u>ចម្លងជូន:</u>
- ក្រសួង រ៉ែ និងថាមពល
- សាលាខេត្តឧត្តរមានជ័យ
- មន្ទីរ រ៉ែ និងថាមពល ខេត្តឧត្តរមានជ័យ
- សាលាស្រុកចុងកាល់
- សាលាឃុំចុងកាល់
- សាលាឃុំជើងទៀន

"ដើម្បីជូនជ្រាប"

- សេវាករ ឈឹម សារពេទ៏ "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ